# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** អញ្ជើញចូលរួមពិធីបញ្ចុះបឋមសិលាសាងសង់រោងចក្រផលិតស៊ីម៉ង់ត៍ របស់ក្រុមហ៊ុន ជីប ម៉ុង អិនស៊ី ស៊ីមេន (CHIPMONG NC Cement) ក្រោមអធិបតីភាព **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា** ភូមិព្រៃតាព្រិត ឃុំស្តេចគង់ខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦។




សមិទ្ធិផលថ្មីមួយនេះ គឺបានឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ ក៏ដូចជាគោលនយោបាយអភិវឌ្ឍឧស្សាហកម្ម របស់ក្រសួងឧស្សាហកម្ម និង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សិប្បកម្ម ការអភិវឌ្ឍវិស័យឧស្សាហកម្ម គឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិយ៉ាងសំខាន់បំផុត ក្នុងកាលៈទេសៈសកលភាវូបនីយកម្ម និងភាពអំណោយផលនៃសុខសន្តិភាពប្រទេសជាតិ។




រោងចក្រថ្មីនេះ នឹងផ្តល់នូវឱកាសការងារថ្មីៗជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងអាចបណ្តុះនូវជំនាញផ្នែកផលិតស៊ីម៉ង់ត៍ជូនដល់បងប្អូន ពិសេសការយល់ដឹងនូវបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗដើម្បីកម្ពុជាមាននូវធនធានមនុស្សដែលមានសមត្ថភាព ឯកទេស ជំនាញពិតប្រាកដ និងអាចធានាបាននូវផលិតផលដែលមានគុណភាព តម្លៃបន្ថែមខ្ពស់ដើម្បីផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។

គួរបញ្ជាក់ថា វិស័យសាងសង់ និងអចលនទ្រព្យនៅកម្ពុជា កំពុងមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ហើយវត្តមានថ្មីនៃរោងចក្រស៊ីម៉ង់ត៍ ជីប ម៉ុង ពិតជាសរបញ្ជាក់ឱ្យឃើញថា កម្ពុជា ជាប្រទេសដ៏មានសក្តានុពល ក្នុងការទាក់ទាញវិនិយោគទាំងក្នុងស្រុក និងពីបរទេសលើគ្រប់វិស័យ ពិសេសវិស័យឧស្សាហកម្ម។

*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**







*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*